# មតិយោបល់របស់អង្គការសង្គមស៊ីវិល សម្រាប់ជាធាតុចូលដល់យុទ្ធនាការចុះបញ្ជីដីរដ្ឋ ដីឯកជនរបស់ប្រជាពលរដ្ឋ ដីសហគមន៍ជនជាតិដើមភាគតិច ការដោះស្រាយវិវាទដីធ្លី និងរៀបចំផែនការប្រើប្រាស់ដី

## សេចក្តីផ្តើម

ឯកសារគោលជំហរនេះ ត្រូវបានរៀបចំឡើង ក្នុងខណៈពេលដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងតែធ្វើយុទ្ធនាការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ នៅទូទាំងខេត្តមណ្ឌលគិរី ដោយចាប់ផ្តើម **ពិធីបើកយុទ្ធនាការចុះបញ្ជីដីធ្លី ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០** ហើយត្រូវបានគេរំពឹងថានឹងអាចបញ្ចប់នៅក្នុងខែ សីហា ២០២០ នេះ ។ យុទ្ធនាការដែលចាប់ផ្តើមនៅខេត្តនេះ ត្រូវបានគេមើលឃើញថា មានការពាក់ព័ន្ធនឹងការចាប់ខ្លួនមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលម្នាក់ ក្នុងបញ្ហាវិវាទដីធ្លីនៅក្នុងខេត្តមណ្ឌលគិរី កាលពីខែកក្កដា កន្លងទៅនេះ ព្រមទាំងករណីរំលោភចាប់យកដីរដ្ឋនិងដីឯកជន ដោយអ្នកមានអំណាចឯទៀតដែលមិនទាន់ដោះស្រាយនៅឡើយនៅក្នុងខេត្តនេះ។ គោលបំណងសំខាន់នៃឯកសារនេះគឺ សំដៅលើកនូវអនុសាសន៍មួយចំនួន ក្នុងការរួមចំណែក ក្នុងដំណើរការនៃការចុះបញ្ជីដីជាប្រព័ន្ធ មិនមែនតែក្នុងខេត្តមណ្ឌលគិរីនោះទេ តែសំដៅទៅលើយុទ្ធនាការលើកក្រោយៗ នៅតំបន់ឬខេត្តដទៃទៀតផងដែរ។ ឯកសារនេះ មានការរៀបរាប់អំពី ១) ប្រវត្តិនៃការបែងចែកដីធ្លីនៅប្រទេសកម្ពុជាកន្លងមក ២) មេរៀន និងបទពិសោធន៍ល្អដែលទទួលបាន ៣) ការប្រឈមកន្លងមក ក៏ដូចជាបច្ចុប្បន្ន ៤) ការលើកឡើងជាអនុសាសន៍ពីសំណាក់អង្គការសង្គមស៊ីវិល និង ៥) បញ្ចប់ដោយសេចក្តីសន្និដ្ឋានសង្ខេប។

## ប្រវត្តិនៃការបែងចែកដីធ្លីនៅប្រទេសកម្ពុជា

ការបែងចែកដីធ្លីនៅប្រទេសកម្ពុជា ត្រូវបានគេកំណត់បែងចែងជា៤ដំណាក់ការ ដោយគិតចាប់ទសវត្សរ៍ទី ៨0 មក។ ១) ការចែកដីលើកទី ១គឺក្នុងទសវត្សរ៍ទី ៨0 ដោយមានការបង្កើតជាក្រុមសាមគ្គី ដែលមានចាប់ពី ១០ ទៅ ១៥គ្រួសារក្នុងមួយក្រុម ក្នុងការប្រើប្រាស់ដី ឧបករណ៍កសិកម្ម និងកម្លាំងអូសទាញរួមគ្នា។ គោលការណ៍នៃការបែងចែក ចេញមកពីមជ្ឈឹមបក្ស និងត្រូវបានអនុវត្ត តាមដោយប្រធានក្រុមសាមគ្គី ។ ដីកសិកម្មជាទ្រព្យសម្បត្តិរបស់រដ្ឋ តែត្រូវបានបែងចែកទៅឱ្យគ្រួសារនីមួយៗនៅក្នុងក្រុមទៅតាមកម្លាំងពលកម្មដែលអាចធ្វើការបាន[1]។ ប៉ុន្តែចាប់តាំងពីឆ្នាំ ១៩៨៦ ក្នុងដំណើការកំណែទម្រង់ គេផ្តល់សិទ្ធិភោគៈសម្រាប់បុគ្គលម្នាក់ៗធ្វើការដាំដុះដំណាំផ្សេងៗ តែក៏មិនអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនដែរ។[2] នៅឆ្នាំ ១៩៨៩ រដ្ឋាភិបាលបានរៀបចំឱ្យ

---

[1] Diepart J.C (2015). The fragmentation of land tenure systems in Cambodia: Peasants and the formalization of land rights

[2] Annual World Bank Conference on Land and Poverty 2013, Old Policies – New Action: A Surprising Political Initiative to Recognize Human Rights in the Cambodian Land Reform, Franz-Volker Müller, Günther Zülsdorf Deutsche Gesellschaft für Internationale Zusammenarbeit (GIZ), Paper prepared for presentation at the "ANNUAL WORLD BANK CONFERENCE ON LAND AND POVERTY", The World Bank - Washington DC, April 8-11, 2013

មាននីតិវិធីចុះបញ្ជីដាច់ដោយដុំ សម្រាប់ដីកសិកម្ម ដោយឆ្លងកាត់ពីរជំហានគឺ ១) អ្នកប្រើប្រាស់ដែលបានចែកដោយរដ្ឋកន្លងមក អាចដាក់ពាក្យស្នើសុំសិទ្ធិភោគៈទៅកាន់ការិយាល័យសុរិយោដី និង ២) មន្ត្រីសុរិយោដីចុះពិនិត្យមើលវាស់វែង រួចដាក់ពាក្យសុំអនុម័តពីអាជ្ញាធរពាក់ព័ន្ធ។ របៀបនេះ ត្រូវបានយកតាមលំនាំប្រទេសបារាំងដែលធ្លាប់ធ្វើកាលពីជាង ៧០ឆ្នាំមុន។ [3]

២) ដំណាក់កាលនេះគិតចាប់ពីឆ្នាំ ១៩៩១ ដល់ ១៩៩៣ ជាដំណាក់ការដែលកងទ័ពស្ម័គ្រចិត្តវៀតណាមបានដកចេញពីកម្ពុជា និង កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលតម្រូវឱ្យមានការគោរពសិទ្ធិមនុស្សទាំងអ្នកនៅក្នុងប្រទេស ជនភៀសខ្លួន និងជនភៀសសឹក ហើយក្នុងនោះក៏មានផ្តោតទៅលើសិទ្ធិលើទ្រព្យសម្បត្តិផងដែរ។ នៅពេលនោះមានការបែងចែកសម្រាប់អ្នកមាតុភូមិនិវត្តន៍មករស់នៅក្នុងសង្គមវិញ

៣) ដំណាក់កាលនេះ កើតឡើងនៅក្នុងឆ្នាំ ១៩៩៨ ក្រោយពីការរលាយអង្គការចាត់តាំងនយោបាយនិងយោធាខ្មែរក្រហម។ សន្តិភាព ក៏ត្រូវបានធានា ហើយដីរដ្ឋត្រូវបានបែងចែកទៅឱ្យអតីតសមាជិកខ្មែរក្រហមដើម្បីចូលរួមក្នុងសង្គមជាតិវិញ។ [4] ចុងបញ្ចប់នៃទសវត្សរ៍ទី ៨០ គឺជាការបញ្ចប់នៃទម្រង់ប្រើប្រាស់ដីបែបសមូហភាព ពោលគឺក្រុមសាមគ្គីតែម្តង ហើយក៏ជាការចាប់ផ្តើមនៅកំណែទម្រង់ដីធ្លីដែរ។ ដីនៅតែជាដីរបស់រដ្ឋ ដូច្នេះគ្មានអ្នកណាម្នាក់មានសិទ្ធិទាមទារដីរបស់ខ្លួនដែលបានប្រើប្រាស់កម្មសិទ្ធិពីមុនឆ្នាំ ១៩៧៩ នោះដែរ។ នៅដំណាក់កាលនេះ រដ្ឋបានបែងចែកដីសម្រាប់ប្រជាពលរដ្ឋ កាន់កាប់ ប្រើប្រាស់ និងលក់ដូរបាន។ ដីដែលបែងចែកនោះមានបីប្រភេទគឺ ដីលំនៅដ្ឋាន ដីកសិកម្ម និងដីសម្បទាន (លើសពី ៥ហិកតា សម្រាប់អភិវឌ្ឍន៍កសិឧស្សាហកម្ម) ។ ដោយសារមានភាពខុសគ្នារវាង ដីភោគៈ កសិកម្ម ដីសម្បទាន និងកម្មសិទ្ធិដីលំនៅដ្ឋាន ទើបនៅឆ្នាំ ១៩៩២ មានការអនុមត័ ច្បាប់ភូមិបាលជាលើកដំបូង ដោយចាត់ទុកដីទាំងអស់ជារបស់រដ្ឋ ហើយប្រជាពលរដ្ឋមានសិទ្ធិភោគៈ។[5] ក្នុងដំណាក់កាលនេះក៏មានការវិវត្តសំខាន់មួយផងដែរគឺ ការធ្វើវិសោធនកម្មច្បាប់ភូមិបាលឆ្នាំ១៩៩២ និងអនុម័តច្បាប់ភូមិបាលថ្មី នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១។ បញ្ញត្តិសំខាន់ៗរួមមាន៖ របបកម្មសិទ្ធិមុនឆ្នាំ១៩៧៩មិនត្រូវបានទទួលស្គាល់ និងមានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលអាចនាំឱ្យបានកម្មសិទ្ធិ។ ភោគៈថ្មីបានបញ្ចប់នៅត្រឹមច្បាប់ភូមិបាលបានចូលជាធរមាន។ គ្មានការចាប់យកដីតាមទំនើងចិត្តណាមួយ អាចកើតឡើងទៅលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈបានឡើយចាប់ពីច្បាប់ភូមិបាលចូលជាធរមាន។ ដោយឡែកក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះ

[3] Diepart J.C (2015). The fragmentation of land tenure systems in Cambodia: Peasants and the formalization of land rights

[4] Annual World Bank Conference on Land and Poverty 2013, Old Policies – New Action: A Surprising Political Initiative to Recognize Human Rights in the Cambodian Land Reform, Franz-Volker Müller, Günther Zülsdorf
Deutsche Gesellschaft für Internationale Zusammenarbeit (GIZ), Paper prepared for presentation at the "ANNUAL WORLD BANK CONFERENCE ON LAND AND POVERTY", The World Bank - Washington DC, April 8-11, 2013

[5] Diepart J.C (2015). The fragmentation of land tenure systems in Cambodia: Peasants and the formalization of land rights

នឹងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់ភូមិបាលឆ្នាំ២០០១។

៤) ដំណាក់កាលនេះ ត្រូវបានអនុវត្ត តាំងពីចុងខែមិថុនា ឆ្នាំ២០១២ គឺជាដំណាក់កាលក្នុងបទបញ្ជា ០១ របស់រាជរដ្ឋាភិបាល ក្រោមទិសស្លោក "គោលនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី " ដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធិពេញលេញ សម្រាប់អ្នកដែលមានដីដែលកំពុងដាំដុះស្រាប់។[6] ដោយឡែក គោលការណ៍បែងចែកដីសម្បទានសង្គមកិច្ចចាប់ពីមានអនុក្រឹត្យ ឆ្នាំ ២០០៣ ក៏បន្តអនុវត្តន៍រហូតដល់បច្ចុប្បន្ន និងអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច ឆ្នាំ២០០៩ ត្រូវបាននិងកំពុងបន្តអនុវត្តន៍រហូតមកដែរ។[7]

## លទ្ធផល និងការប្រឈមនៃការបែងចែកដីតាមបទបញ្ជា ០១ ការបែងចែកដីសម្បទានសង្គមកិច្ច និង ការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច

### បទបញ្ជា ០១

កម្មវិធីនេះត្រូវបានអនុវត្ត ពី ខែ មិថុនា ២០១២ ដល់ ខែធ្នូ ឆ្នាំ ២០១៤ ដោយក្រុមនិស្សិតស្ម័គ្រចិត្តប្រមាណ ១១00នាក់ ហើយបានសម្រេចលទ្ធផលគ្របដណ្តប់លើផ្ទៃដី ១,២ លានហិកតា និងបានផ្តល់ប័ណ្ណកម្មសិទ្ធិប្រមាណ ៦១០.000 ។ កម្មវិធីនេះ រួមជាមួយវិធានការផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាទាក់ទងទៅនឹងការអនុវត្ត ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ។ ទោះបីការអនុវត្ត មិនមានភាពរលូនក៏ដោយ ផ្ទៃដីមួយផ្នែកធំត្រូវបានកាត់ចេញពីដីសម្បទានសេដ្ឋកិច្ច អតីតព្រៃសម្បទាន ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងតំបន់ការពារធម្មជាតិមួយចំនួន។ ការផ្តល់ប័ណ្ណកម្មសិទ្ធិចំពោះប្រជាពលរដ្ឋ ដែលត្រូវប្រឈមពីការបណ្តេញចេញ ជាពិសេសជនក្រីក្រនៅតំបន់ជនបទ និងបានព្យួរចំពោះការអនុម័តឱ្យមានសម្បទានដីសេដ្ឋកិច្ចថ្មីៗដែលនៅជាធរមាននៅឡើយ។ [8]

ទន្ទឹមហ្នឹងការជោគជ័យនេះ រួមមានទាំងអ្នកពេញចិត្តយ៉ាងច្រើន (ជាង ៦០%នៃអ្នកចូលរួមសម្ភាសន៍) ហើយទំនាស់ក៏បានថយចុះគួរឱ្យកត់សម្គាល់ ក៏បាននាំមកនូវកង្វះចន្លោះ និងការព្រួយបារម្ភជាច្រើនដែរ។ ១) កង្វះការផ្តល់ឱកាសចូលរួមដល់អង្គការសង្គមស៊ីវិល ក៏ដូចជាដៃគូអភិវឌ្ឍន៍ ក្នុងការតាមដានការអនុវត្ត ឬការចូលរួមជួយផ្សព្វផ្សាយបទបញ្ជា ០១ ដែលជាហេតុនាំឱ្យមានការពិបាក ក្នុងការវាយតម្លៃអំពីគុណភាពនៃដំណើរការទាំងមូល។ ២) ការរៀបចំផែនការលម្អិត គួរតែត្រូវបានធ្វើឱ្យច្បាស់លាស់សិន មុនពេលចុះវាស់វែង ព្រោះជាក់ស្តែងត្រូវបានអនុវត្ត នៅខែកក្កដា ឆ្នាំ២០១២ តែម្តង យោងតាមសារាចរណ៍ណែនាំលេខ ១០៨ របស់ក្រុម

---

[6] Annual World Bank Conference on Land and Poverty 2013, Old Policies – New Action: A Surprising Political Initiative to Recognize Human Rights in the Cambodian Land Reform, Franz-Volker Müller, Günther Zülsdorf Deutsche Gesellschaft für Internationale Zusammenarbeit (GIZ), Paper prepared for presentation at the "ANNUAL WORLD BANK CONFERENCE ON LAND AND POVERTY", The World Bank - Washington DC, April 8-11, 2013

[7] ibid.

[8] Grimsditch, M; Schoenberger, L. and Meas, N. (2015). New Actions and Existing Policies: The Implementation and Impacts of Order 01, NGO Forum on Cambodia

ប្រឹក្សាគោលនយោបាយដីធ្លី។ ការអនុវត្ត ក្នុងស្ថានភាពប្រញាប់ មានផលប៉ះពាល់ ដោយសារក្រុមវាស់វែង មិនបានយល់អំពីប្រភេទ និងចំណាត់ថ្នាក់ដីឱ្យបានស៊ីជម្រៅ ធ្វើឱ្យការវាស់វែងចូលទៅដល់ដីគម្របព្រៃឈើ ដូចជាករណីនៅខេត្តឧត្តរមានជ័យជាដើម។ ៣) ការផ្តល់ប័ណ្ណទៅឱ្យអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់ (មានអ្នកខ្លះរហូតជាង ២០ឆ្នាំ) ដូចជាដីគម្របព្រៃ ឬដីព្រៃការពារ តែមានភាគតិចណាស់ ដែលទទួលបានព័ត៌មានថា ខ្លួនរស់នៅលើដីខុសច្បាប់។ ៤) ការអនុវត្ត មានបញ្ហានៅតំបន់ជនជាតិដើមភាគតិច ដោយសារការត្រៀមលក្ខណៈរបស់ក្រុមនិស្សិតវាស់វែងមិនបានគ្រប់គ្រាន់ ជាពិសេសក្រោយពីការអនុវត្ត យុទ្ធនាការប្រហែលបានមួយខែរួចហើយ ទើបមានចេញសេចក្តីណែនាំមិនឱ្យមានការវាស់វែងដីសមូហភាពពីដំណើរការទាំងមូល តែអនុញ្ញាតឱ្យជនជាតិដើមភាគតិច ទទួលយកកម្មសិទ្ធិឯកជន និងលះបង់សិទ្ធិលើដីសមូហភាព ដោយមានការបំភ័យ ឬតម្រូវឱ្យទទួលយកតែម្តង ព្រោះថាកម្មសិទ្ធិសមូហភាពត្រូវរង់ចាំយូរ ក្នុងខណៈដែលសម្ពាធពីឈ្មួញទិញដីកាន់តែកើនឡើង។ ជនជាតិដើមភាគតិចមួយចំនួនបានជ្រើសរើសយកកម្មសិទ្ធិឯកជន ដែលនេះមានហានិភ័យទៅលើការបែកបាក់សាមគ្គីភាព និងការថែរក្សាវប្បធម៌ប្រពៃណីរបស់ខ្លួន ដោយសារតែមានការចោទឆ្លើយដាក់អ្នកទទួលយកកម្មសិទ្ធិឯកជនបានធ្វើឱ្យខូច ឬរាំងស្ទះដល់ផែនការចុះបញ្ជីដីជាសមូហភាព។[9] ៥) ករណីខ្លះដូចជាការមិនមានព្រំប្រទល់រដ្ឋបាលច្បាស់លាស់រវាងខេត្តមណ្ឌលគិរី និងក្រចេះ នាំឱ្យសហគមន៍ជនជាតិដើមភាគតិចបាត់បង់ឱកាសលើធនធានដែលធ្លាប់បានប្រើប្រាស់ ដោយសារការទទួលយកដីឯកជន។[10] ៦) គ្រួសារខ្លះមិនស្គាល់ព្រំដី និងអ្នកនៅជាប់ព្រំដីច្បាស់លាស់ ដែលនាំឱ្យមានការពិបាកក្នុងការវាស់វែង ព្រោះត្រូវមានស្នាមមេដៃអ្នកពាក់ព័ន្ធ។ លើសពីនេះទៅទៀតគឺ ម្ចាស់ដីដែលបានចេញទៅប្រកបការងារនៅខេត្តដទៃ ឬក្រៅប្រទេស មិនបានទទួលព័ត៌មានទាន់ពេលវេលា ដែលនាំឱ្យមានការខកខាន។[11]

## ការបែងចែកដីសម្បទានសង្គមកិច្ច

ភាពគ្មានដីធ្លី ជាបញ្ហាមួយតាំងពីទសវត្សរ៍ទី ៩០ ហើយបញ្ហានេះ កាន់តែរីកធំឡើងដោយសារជនមាតុភូមិនិវត្តន៍មកពីតាមព្រំដែនកម្ពុជា-ថៃ ការបាត់បង់ដីដោយការលក់ដូរ និងកំណើននៃកងទ័ពរំសាយ។ ដោយសារចាប់យកដីទំនេរមកប្រើប្រាស់ ត្រូវបានចាត់ទុកថាជា ទង្វើខុសច្បាប់ គិតចាប់តាំងពីឆ្នាំ ២០០១ មក ទើបបង្កើតឱ្យមានយន្តការបែងចែកដីធ្លីជាថ្មី តាមរូបភាពសម្បទានដីសង្គមកិច្ច ដោយការផ្ទេរដីឯកជនរបស់រដ្ឋជូនគ្រួសារដែលគ្មានដី សម្រាប់ជាលំនៅដ្ឋាន និងដីដាំដុះកសិកម្ម។ សម្បទានដីសង្គមកិច្ចចែកជាពីរកម្រិតគឺ ការផ្តួចផ្តើមគំនិតនៅមូលដ្ឋានដោយក្រុមប្រឹក្សាឃុំ និង នៅថ្នាក់ជាតិដោយក្រសួងពាក់ព័ន្ធ។ សម្បទានដីស

[9] DIRECTIVE 01BB IMPACT ASSESSMENT REPORT, Private land titling by the youth student volunteers in Ratanakiri Province, *Assessing issues during the demarcation process and effects on indigenous communities,* By: Alison Rabe, SVC Advisor, February 2013

[10] Note of interviews by Sek Sorphorn and Chea Phalla, ILO, Impact Assessment of PM Directive 01 on Indigenous Collective Land Registration, *21 December 2012*

[11] "Moving Forward: Study on the Impacts of the Implementation of Order 01BB in Selected Communities in Rural Cambodia", June 2013, *Study on the Impacts of the Implementation of Order 01BB on Selected Communities in Rural Cambodia*

ង្គមកិច្ច ស្រដៀងទៅនឹងភោគៈ ជាពិសេសក្នុងរយៈពេល៥ឆ្នាំដំបូង។ នៅពេលដែលសម្បទានិករស់នៅលើដី ៥ឆ្នាំ និងគោរពតាមគោលការណ៍ សម្បទានិកអាចដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិបាន។ គិតមកត្រឹមខែ មិថុនា ឆ្នាំ ២០១៤ សម្បទានិកមានចំនួន ១២.៣៧៤ គ្រួសារ គ្រប់ដណ្តប់លើផ្ទៃដីសសរុប ១១៣.១៦៧ ហិកតា (ដីលំនៅដ្ឋាន ដីដាំដុះ និង ហេដ្ឋារចនាសម្ព័ន្ធ)។[12]

អនុក្រឹត្យសម្រាប់សម្បទានដីសង្គមកិច្ច ត្រូវបានអនុម័តតាំងពីឆ្នាំ២០០៣ ជាយន្តការផ្ទេរដីរដ្ឋទៅដល់គ្រួសារក្រីក្រសម្រាប់លំនៅដ្ឋាន និងការដាំដុះ។ កម្មវិធីសាកល្បង៥ឆ្នាំដំបូង ត្រូវបានធ្វើឡើងនៅខេត្តកំពង់ចាម កំពង់ធំ និងក្រចេះ គាំទ្រដោយធនាគារពិភពលោក និង អង្គការ GIZ ។ កម្មវិធីពង្រឹងអភិបាលកិច្ចល្អ ក្នុងការបែងចែកដីធ្លី ត្រូវបានវាយតម្លៃខ្ពស់ចំពោះភាពជោគជ័យនៃគម្រោងដោយសារតែមានការសហការគ្នាជិតស្និទ្ធជាមួយមន្ត្រីគ្រប់លំដាប់ថ្នាក់ជាមួយអង្គការ និងតំណាងសហគមន៍នៅក្នុងតំបន់ដីសម្បទាន តែក៏ទាមទារឱ្យមានការយកចិត្តទុកដាក់ទៅលើគ្រួសារកង្វះដីពិតប្រាកដ ចំណាយពលកម្ម ដើម្បីជីវភាពប្រចាំថ្ងៃ ដើម្បីរាប់បញ្ចូលមកក្នុងគម្រោង និងការរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព ទឹកស្អាត និងកម្មវិធីលើកកម្ពស់ជីវភាពឱ្យបានពីគ្រាដំបូងគឺជាការចាំបាច់[13]។

ដោយឡែកឯកសារស្រាវជ្រាវដែលបានដាក់ផ្សាយជាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ធនាគារពិភពលោក ក៏បានរកឃើញដែរថា ១) ការអនុវត្តនីតិវិធីកំណត់អត្តសញ្ញាណដីធ្លី ត្រូវបានអនុវត្តយ៉ាងជោគជ័យ ក្នុងការជៀសវាងផលប៉ះពាល់អវិជ្ជមានដល់អ្នកប្រើប្រាស់ដីដែលមានស្រាប់។ ការទាមទារដីដែលខ្លួនកាន់កាប់មុនពេលគម្រោងចាប់ផ្តើម (ទោះពុំមានប័ណ្ណកម្មសិទ្ធិ) ត្រូវបានកំណត់មុខសញ្ញា និង មិនត្រូវបានរាប់បញ្ចូលក្នុងគម្រោង តាមរយៈដំណើរការប្រកបដោយតម្លាភាព និងមានការពិគ្រោះយោបល់ ២) ជៀសវាងផលប៉ះពាល់ជាអវិជ្ជមានដល់អ្នកប្រើប្រាស់ដី ពីលទ្ធកម្មដីសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយសារបានធ្វើផែនការ ប្រើប្រាស់ដីធ្លីដែលបែងចែកដីទំនេរសម្រាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធ ហើយក៏មានការរៀបចំការដោះដូរដី ជាមួយអ្នកប្រើប្រាស់ដីមួយចំនួនតូចដែរ និង ៣) យន្តការដោះស្រាយពាក្យបណ្តឹង មិនបានឆ្លើយតបពេញលេញទៅនឹងបណ្តឹងដ៏ច្រើននោះទេ។ តាមពិត ដំណើរការនៃកំណត់អត្តសញ្ញាណ និងការបែងចែកដីធ្លីតែងតែកើតមាននៅការទាមទារ ឬតវ៉ា។ ប្រសិនបើស្ថាប័នអនុវត្តន៍គម្រោង មិនអាចធ្វើបាន ជម្រើសមួយទៀតគឺ ប្រគល់ការងារនេះទៅឱ្យភ្នាក់ងារផ្តល់សេវាវិញ[14]។

## ការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច

រាជរដ្ឋាភិបាលទទួលស្គាល់សិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច តាមរយៈការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាព។ កម្មវិធីនេះជាជម្រើសសំខាន់សម្រាប់សហគមន៍ជនជាតិដើមភាគតិច ដើម្បីការពារដីធ្លី ធនធាន

[12] Diepart J.C (2015). The fragmentation of land tenure systems in Cambodia: Peasants and the formalization of land rights

[13] End project evaluation report, Wathanakpheap, 2013

[14] Environmental and Social Management Framework (ESMF), LASED-III Preparation, 2020

ធម្មជាតិ និងរក្សាវប្បធម៌ប្រពៃណីរបស់ពួកគាត់។ ដោយសារតែភាពងាយរងគ្រោះរបស់ពួកគាត់ ការជំរុញការអនុវត្ត វិធានការពារបណ្តោះអាសន្ន មុនពេលចុះបញ្ជីជាផ្លូវការ ជាការងារចាំបាច់ ដើម្បីធានានិរន្តរភាពនៃការកាន់កាប់ និងប្រើប្រាស់ដីតាមលក្ខណៈប្រពៃណី។ លុះពេលគាត់បានកម្មសិទ្ធិជាផ្លូវការ ពួកគាត់មានសិទ្ធិស្របច្បាប់ អាចដាក់ពាក្យបណ្តឹង ទៅកាន់តុលាការ ដើម្បីដោះស្រាយបញ្ហា ជាពិសេសការរំលោភបំពានចូលព្រំដី និងការបំផ្លាញព្រៃឈើរបស់សហគមន៍ជាដើម។

សិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា ជាពិសេស សិទ្ធិទទួលបានធនធានដីធ្លី ត្រូវបានទទួលស្គាល់ជាផ្លូវការនៅក្នុងច្បាប់ភូមិបាល ឆ្នាំ២០០១ ។ លើសពីនេះទៀត អនុក្រឹត្យលេខ ៨៣ (២០០៩) ស្តីពី "នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច" ដែលស្របទៅនឹងច្បាប់ស្តីពីព្រៃឈើ (២០០២) និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ បង្ហាញនូវបញ្ញត្តិ និងគោលការណ៍ណែនាំលម្អិតស្តីពី វិធីដែលជនជាតិដើមភាគតិច អាចចុះបញ្ជីដីសហគមន៍បាន។ ជាទូទៅ ដំណើរការចុះបញ្ជីត្រូវឆ្លងកាត់ដំណាក់កាលបីសំខាន់គឺ ១) ការទទួលស្គាល់អត្តសញ្ញាណសហគមន៍ពីសំណាក់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលមកដល់ពេលនេះ បាន ១៥០ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៩ ២) ការចុះបញ្ជីសហគមន៍ជានីតិបុគ្គលដោយក្រសួងមហាផ្ទៃ ដែលគិតមកដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ នេះ បានចំនួន ១៥០សហគមន៍ និង ៣) ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលគិតមកដល់ដំណាច់ខែធ្នូ ឆ្នាំ២០១៩ បានចំនួន ៣០សហគមន៍ ក្នុងចំណោម សហគមន៍ជនជាតិដើមភាគតិចដែលបានដាក់ពាក្យស្នើសុំចំនួន ៦៨ ។[15] សហគមន៍ជនជាតិដើមភាគតិចដែលមិនទាន់បានគ្របដណ្តប់ អាចមានហានិភ័យខ្ពស់ជាងគេពីការបាត់បង់អត្តសញ្ញាណ វប្បធម៌ សិទ្ធិ និងវិវាទលើដីធ្លី ដែលអាចបង្កជាហានិភ័យខ្ពស់ដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ។

នៅមានការប្រឈមសំខាន់ៗចំពោះសហគមន៍ជនជាតិដើមភាគតិចរួមមាន ១) ការយល់ដឹងអំពីនីតិវិធី និងដំណើរការចុះបញ្ជីភាគច្រើន មានតែក្នុងរង្វង់ថ្នាក់ដឹកនាំសហគមន៍ តែសមាជិកសហគមន៍ពុំសូវមានការយល់ដឹងនោះទេ។ ហេតុនេះហើយបានជាមានការរារែកក្នុងចំណោមសមាជិកសហគមន៍ថាតើត្រូវចុះបញ្ជីដីសមូហភាព ឬចុះជាដីឯកជន ដែលជាហានិភ័យមួយក្នុងការបាត់ឱកាសរក្សា គ្រប់គ្រង អភិវឌ្ឍន៍ដីក្នុងរយៈពេលវែង។ ២)ការត្រួតស៊ីគ្នារវាងដីសហគមន៍ដែលអះអាងថាជាដីប្រកបរបរកសិកម្មប្រពៃណី និងចំណាត់ថ្នាក់ដីរដ្ឋក្នុងតំបន់ការពារធម្មជាតិដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ឬសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ដែលគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ហេតុនេះព័ត៌មានអំពីការត្រួតស៊ីគ្នា ទាមទារឱ្យមានការសិក្សា សម្របសម្រួលរវាងសហគមន៍ និងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់បែងចែកតំបន់គ្រប់គ្រង ឬធ្វើ

15 Thol, D. & Oeur, I. (2019) A Decade of Communal Land Titling in Cambodia: Achievements and Ways Forwards. Cambodia Journal of Basic and Applied Research (CJBAR), 1(2), 06–15. Royal University of Phnom Penh.

ចំណាត់ថ្នាក់ក្នុងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យបានច្បាស់លាស់ យោងតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ភូមិបាល និងច្បាប់ស្តីពីព្រៃឈើ មុននឹងដីចុះបញ្ជីដីសហគមន៍ជាផ្លូវការ។ ៣) ការរៀបចំផែនទីបឋមក៏មានភាពស្មុគ្រស្មាញ ហើយចំណាយពេលច្រើនដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល និងមន្ត្រីភូមិបាល ទោះបីពុំមានច្បាប់ ឬនីតិវិធីកំណត់នៅក្នុងដំណើការនេះក៏ដោយ។

## ក្របខណ្ឌគតិយុត្ត និងការរៀបចំរចនាសម្ព័ន្ធអនុវត្តន៍យុទ្ធនាការសម្រាប់ខេត្តមណ្ឌលគិរី

យុទ្ធនាការនេះ ត្រូវបានអនុលោមតាមច្បាប់ និងគោលការណ៍ពាក់ព័ន្ធ ហើយក្រសួងពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលខេត្តមណ្ឌលគិរីបានចេញសេចក្តីណែនាំ និងលិខិតជូនដំណឹងតាមពេលវេលា ជាបន្តបន្ទាប់នៅក្នុងខែកក្កដា ឆ្នាំ ២០២០ សម្រាប់ធានាប្រសិទ្ធភាពនៃការអនុវត្តន៍យុទ្ធនាការនេះ ដូចមានលទ្ធផលខាងក្រោមៈ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្តីសម្រេចលេខ២៦៩សសរ កសក ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ស្តីពីការបង្កើតក្រុមការងារចុះសិក្សាស្រាវជ្រាវ និងផ្ទៀងផ្ទាត់ទិន្នន័យដីព្រៃដែលប្រជាពលរដ្ឋកាន់កាប់អាស្រ័យផលជាក់ស្តែងមានចំនួនចំនួន ១៨ ក្រុមទូទាំងប្រទេស។

ពីរថ្ងៃបន្ទាប់មក ក្រសួងមហាផ្ទៃ បានចេញលិខិតលេខ១៩៦៣ សជណចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ជម្រាប មកអភិបាលនៃគណៈអភិបាលខេត្តទាំងអស់ ស្តីពីការជំរុញការទប់ស្កាត់ ការកាប់រានទន្ទ្រានយកដីដោយខុសច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ នៅតាមខេត្តនានា។ ៧ថ្ងៃបន្ទាប់មករដ្ឋបាលខេត្តមណ្ឌលគិរីបានចេញលិខិតលេខ០៨០/របក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ផ្ញើលិខិតសំណើសុំបញ្ជូនទិន្នន័យតួលេខប៉ាន់ស្មានជាបឋម អំពីស្ថិតិប្រជាជន និងផ្ទៃដីដែលត្រូវបានកាន់កាប់ និងអាស្រ័យផលនៅក្នុងតំបន់ការពារធម្មជាតិ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី មកកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ទិន្នន័យបឋម ប្រជាពលរដ្ឋប៉ាន់ស្មានមានចំនួន ១០.៧៧២គ្រួសារកាន់កាប់លើផ្ទៃដីប្រហែល ៣៩.១៥៨,២០ ហិកតា នៅក្រុងស្រុកចំនួន៥នៃខេត្តមណ្ឌលគិរី ។

មួយថ្ងៃបន្ទាប់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញលិខិតលេខ២១៦០ ដនស/អសដក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីការជម្រាបជូនអភិបាលខេត្តមណ្ឌលគិរី ដោយស្នើសុំកិច្ចសហការជំរុញចុះបញ្ជីដីរដ្ឋ ដីឯកជនរបស់ប្រជាពលរដ្ឋ ដីសហគមន៍ជនជាតិដើមភាគតិច ការដោះស្រាយវិវាទដីធ្លី និងរៀបចំផែនការប្រើប្រាស់ដីនៅខេត្តមណ្ឌលគិរី ។ មួយថ្ងៃបន្ទាប់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញលិខិតលេខ២១៦៦ដនស/អសដក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីសំណើរៀបចំកិច្ចប្រជុំអំពីការអនុវត្តការងារចុះបញ្ជីដីរដ្ឋ ដីឯកជនរបស់ប្រជាពលរដ្ឋ ដីសហគមន៍ជនជាតិដើមភាគតិច ដោះស្រាយវិវាទដីធ្លី និងកសាងផែនការប្រើប្រាស់ដីធ្លីនៅខេត្តមណ្ឌលគិរី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ជូនដល់អភិបាលខេត្តមណ្ឌលគិរី ។ នៅថ្ងៃនោះដែរ រដ្ឋបាលខេត្តមណ្ឌលគិរីបានចេញ

លិខិតបង្គាប់ការលេខ០៥១/២០ លបក ចុះថ្ងៃទី១៧ ខែកក្កដាឆ្នាំ២០២០ ជូនដល់មន្ត្រីចំនួន៨រូបដឹកនាំដោយ លោក សុក សេរ៉ា នាយករងរដ្ឋបាលសាលាខេត្តដើម្បីចុះពិនិត្យទីតាំងដីនៅឃុំស្រែព្រះ ស្រុកកែវសីមាខេត្តមណ្ឌលគិរី សម្រាប់ប្រជាពលរដ្ឋ៥០គ្រួសាររស់នៅក្នុងឃុំកក់ ស្រុកពេជ្រាដ្ឋា ខេត្តត្បូងឃ្មុំដែលគ្មានដីបង្កបង្កើនផល។

នៅថ្ងៃនោះដែរ ក្រសួងបរិស្ថាន បានចេញលិខិតលេខ០៥៤ ស.ស.រ...ប.ស្ថ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០២០ស្តីពី ការបង្កើតក្រុមការងារក្រសួងបរិស្ថានចំនួន១៤ ក្រុម សម្រាប់ត្រួតពិនិត្យ សិក្សា និងចងក្រងឯកសារទីតាំងដីដែលប្រជាពលរដ្ឋបានប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចំរុះ។ នេះជាការត្រៀមលក្ខណៈដ៏សំខាន់ ដើម្បីជៀសវាងការវាស់វែងដែលអាចត្រួតស៊ីគ្នារវាងដីឯកជន ដីសមូហភាព និងដីរដ្ឋ។ ជាក់ស្តែង នាពេលកន្លងមក លទ្ធផលនៃការវាស់វែងដីជាលក្ខណៈប្រព័ន្ធ នៅភូមិស្រែអ៊ីនៃខេត្តមណ្ឌលគិរី ត្រូវបានមន្ទីរបរិស្ថានខេត្តចេញលិខិតលេខ៣៤១/២០ ស.ណ..បស្ថ មករចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ មានកម្មវត្ថុសំណើសូមជំទាស់ឯកសារនៃលទ្ធផលវាស់វែងដីធ្លីរបស់ក្រុមការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដោយសារទីតាំងក្បាលដី និងទីតាំងភូមិសាស្ត្រមួយចំនួន ស្ថិតនៅក្នុងគម្រោងរ៉េដបូកនៃដែនជម្រកសត្វព្រៃកែវសីមាដែលកំពុងដំណើការកំណត់បែងចែកតំបន់គ្រប់គ្រង។

ក្រសួងបរិស្ថាន បានចេញសេចក្តីណែនាំលេខ០០៥ សណន...បស្ថ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីគោលការណ៍ចុះពិនិត្យសិក្សា និងចងក្រងឯកសារទីតាំងដីកាត់ឆ្វៀលជូនប្រជាពលរដ្ឋដែលបានប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែងនៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងជីវចម្រុះ ទៅដល់មន្ត្រីក្រុមការងាររបស់ក្រសួង និងមន្ទីរបរិស្ថាន។ ក្នុងថ្ងៃនោះដែរ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញសេចក្តីសម្រេច លេខ០៣៩ សសរចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីការបង្កើតគណៈកម្មការគាំទ្រការចុះបញ្ជីដីរដ្ឋ ដីឯកជនរបស់ប្រជាពលរដ្ឋ ដីសហគមន៍ជនជាតិដើមភាគតិច ដោះស្រាយវិវាទដីធ្លី និងរៀបចំផែនការប្រើប្រាស់ដីធ្លី នៅខេត្តមណ្ឌលគិរី។

មួយថ្ងៃបន្ទាប់ រដ្ឋបាខេត្តមណ្ឌលគិរី ក៏បានចេញសេចក្តីជូនដំណឹងលេខ០៩៧/២០សជណ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីការវាស់វែងចុះបញ្ជីដីរដ្ឋ ចុះបញ្ជីដីប្រជាពលរដ្ឋ ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជូនដល់សាធារណៈជន គ្រប់ស្ថាប័នរដ្ឋ ភ្នាក់ងារហិរញ្ញវត្ថុនានា អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋចូលរួម បោះព្រំដី ត្រៀមឯកសារពាក់ព័ន្ធ ដោះស្រាយវិវាទ ហាមការកាប់រានដីព្រៃបន្ថែម។ នៅថ្ងៃដដែល រដ្ឋបាលខេត្តមណ្ឌលគិរី ក៏បានចេញសេចក្តីជូនដំណឹងចំនួន១០ដាច់ដោយឡែកពីគ្នាលេខ១០១/២០ សជណ ១០៨/២០ សជណ ១០៥/២០សជណ ១០៧/២០ សជណ ១៩៨/២០ សជណ ០៨៨/២០ សជណ ១០២/២០ សជណ ១០២/២០សជណ ១០៤/២០ សជណ និង ១០៦/២០ សជណ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២០ស្តីពីកិច្ចប្រជុំផ្សព្វផ្សាយប្រកាសកំណត់តំបន់វិនិច្ឆ័យចុះបញ្ជីដីធ្លីលក្ខណៈប្រព័ន្ធនៅភូមិចំនួន១០រួម

មានភូមិអូរប្រា ភូមិហ្កាទី ភូមិស្រែអំពិល ភូមិពូហ្សាម ភូមិណងប៊្លូ ភូមិដីមៀត ភូមិកោះម្សៀលលើ ភូមិកោះម្សៀលក្រោម ភូមិឡោវមៀត និងភូមិពូលូង។

នៅថ្នាក់ជាតិតាមរយៈក្រសួងមហាផ្ទៃ បានចេញសេចក្ដីសម្រេច លេខ៣១៣៩ សជណចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ស្ដីពី «ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចុះសិក្សាស្រាវជ្រាវ លើករណីការកាប់រាន ទន្ទ្រានកាន់កាប់ដីព្រៃខុសច្បាប់ ក្នុងតំបន់ការពារធម្មជាតិ ស្ថិតក្នុងខេត្តមណ្ឌលគិរី ដោយមានតួនាទី និង ភារកិច្ច លើការចុះសិក្សាស្រាវជ្រាវលើករណីនីមួយៗនៃការកាប់រាន ទន្ទ្រានកាន់កាប់ដីព្រៃខុសច្បាប់ ក្នុងតំបន់ការពារធម្មជាតិ ស្ថិតក្នុងខេត្តមណ្ឌលគិរី ដែលមានសមាសភាពចំនួន១៣រូប រួមមានក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដឹកនាំអនុវត្ត ដោយក្រសួងមហាផ្ទៃ។

បន្ទាប់ពីនេះភ្លាម រដ្ឋបាលស្រុកអូររាំង ក៏បានចេញសេចក្ដីជូនដំណឹងដល់ប្រជាពលរដ្ឋដែលមិន ទាន់បានចុះបញ្ជីដី ឬកំពុងមានវិវាទតាមលិខិតលេខ១៨៨/២០ សជណ.សអរ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២០ ស្ដីពីការវាស់វែងចុះបញ្ជីដីរដ្ឋ ដីប្រជាពលរដ្ឋ និងដីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងស្រុកអូររាំងដែលពុំទាន់បានចុះបញ្ជី និងកំពុងមានវិវាទមិនទាន់ដោះស្រាយចប់ ឱ្យមកដាក់ពាក្យបណ្ដឹងនៅការិយាល័យនីតិកម្ម និងដោះស្រាយវិវាទនៃរដ្ឋបាលស្រុកអូររាំង ចាប់ពីថ្ងៃទី៣០ ខែកក្កដា ដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០។

អភិបាលខេត្តមណ្ឌលគិរីក៏បានចេញលិខិតសំណើររៀបចំកិច្ចប្រជុំថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២០ អំពី ការអនុវត្ត ចុះបញ្ជីដីរដ្ឋ ដីឯកជនរបស់ប្រជាពលរដ្ឋ ដីសហគមន៍ជនជាតិដើមភាគតិច ការដោះស្រាយវិវាទដីធ្លី និងរៀបចំផែនការប្រើប្រាស់ដីនៅខេត្តមណ្ឌលគិរី។ យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងរៀបចំដែនដីចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ថា មានក្រុមការងារអន្តរក្រសួងចំនួន ៥៥០នាក់ ក្នុងនោះមានក្រុមការងារវាស់វែងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រមាណ ៣០០នាក់ ក្រសួងបរិស្ថានចំនួនប្រមាណ ២០០នាក់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួនប្រមាណ៥០នាក់ ដោយប្រើប្រាស់ឧបករណ៍ T300 PLUS GNSS កំពុងមានវត្តមានក្នុងយុទ្ធនាការនៅក្នុងខេត្តមណ្ឌលគិរី។ ក្រុមការងារនឹងស្នាក់នៅទីតាំងចំនួន ៣៧កន្លែង។

បន្ទាប់ពីអនុវត្តបានរយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី២៩ ខែកក្កដា ដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២០ នៅតាមភូមិគោលដៅ រដ្ឋបាលខេត្តមណ្ឌលគិរីបានចេញសេចក្ដីជូនដំណឹងលេខ ១៣៤/២០ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០២០ ស្ដីពីការផ្អាកសកម្មភាពជាបណ្ដោះអាសន្នរបស់ក្រុមការងារចុះបញ្ជីដីរដ្ឋ ដីឯកជនរបស់ប្រជាពលរដ្ឋ ដីសហគមន៍ជនជាតិដើមភាគតិច ការដោះស្រាយវិវាទដីធ្លី និងគាំទ្រការរៀបចំផែនការប្រើប្រាស់ដីនៅខេត្តមណ្ឌលគិរី បានសម្រេចផ្អាកសកម្មភាពអនុវត្តការងារមួយរយៈពេលសិន ដោយសារមូលហេតុអាកាសធាតុ។ រដ្ឋបាលខេត្តនឹងជូនដំណឹងអំពីកាលបរិច្ឆេទចាប់ផ្ដើមអនុវត្តការងារបន្តនៅពេលក្រោយ។

## ឱកាស និង ហានិភ័យ ឬផលវិបាកដែលអាចកើតមានពីយុទ្ធនាការបែបនេះ ឬ ប្រហាក់ប្រហែល

តើការអនុវត្ត យុទ្ធនាការបែបនេះ (ទាំងនៅមណ្ឌលគិរី និងនៅតំបន់ផ្សេងៗលើកក្រោយទៀត) អាចមានផលប៉ះពាល់ ឬនាំមកនូវហានិភ័យបែបណាខ្លះ សម្រាប់ការងារចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច ក្នុងតំបន់ការពារធម្មជាតិ ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និង មកលើការអនុវត្ត គម្រោង LASED III (គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច) របស់រាជរដ្ឋាភិបាល ក្នុងពេលខាងមុខទៀត?

- សេចក្តីសម្រេច សេចក្តីណែនាំ និងសេចក្តីជូនដំណឹងពាក់ព័ន្ធរបស់ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលខេត្តមណ្ឌលគិរីឆ្លុះបញ្ចាំងឱ្យឃើញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ឱ្យបានទាន់ពេលវេលា ដោះស្រាយបញ្ហាប្រឈមនៃការកាប់រានទន្រ្ទានដីតំបន់ការពារធម្មជាតិតាមរយៈការអនុវត្ត សុខដុមនីយកម្មនៃនីតិវិធីអនុក្រឹត្យចំនួនបីរួមមាន អនុក្រឹតលេខ១១៨ស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹតលេខ៤៦ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ក្នុងការអនុវត្តជាក់ស្តែងនៅទីវាល មន្រ្តីក្រុមការងារមួយចំនួនបានយល់ដឹង ពីក្របខ័ណ្ឌចុះបញ្ជីដីរដ្ឋ ដីសហគមន៍ជនជាតិដើមភាគតិច និងដីកាន់កាប់ឯកជនដោយពលរដ្ឋ ប៉ុន្តែពួកគេអនុវត្តតាមនីតិវិធីនៃអនុក្រឹត្យលេខ៤៦ទាំងស្រុងក្នុងសហគមន៍ជនជាតិដើមភាគតិច ដែលជាហេតុជំរុញពួកគេសុំកម្មសិទ្ធិឯកជន។
- យោងតាមលិខិតបទដ្ឋានខាងលើ យើងសង្កេតឃើញថា ការងារចុះបញ្ជីដីនៅក្នុងខេត្តមណ្ឌលគិរីមានលក្ខណៈប្រញាប់ប្រញាល់ស្របជាមួយនឹងកំណើននៃការកាប់រាន និងទិញលក់ដូរដីក្នុងតំបន់ការពារធម្មជាតិ និងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ។ ទោះបីវាមានគោលបំណងល្អ ហើយការអនុវត្ត នេះដោយមន្ត្រីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលមានជំនាញ និងបទពិសោធន៍នៃការវាស់វែងដី តែពួកគេពិតជាមានបទពិសោធន៍ និងការយល់ដឹងតិចតួចទៅលើបរិបទនៅមូលដ្ឋាន។ ឧទាហរណ៍ នៅក្នុងខេត្តមណ្ឌលគិរី មានកម្មវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាច្រើនឆ្នាំកន្លងមក ហើយសហគមន៍នីមួយៗស្ថិតនៅក្នុងដំណាក់កាលនៃការចុះបញ្ជីក្នុងកម្រិតផ្សេងៗពីគ្នា ក្រៅពីនេះក៏មានសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិដែលសុទ្ធតែមានបែបផែនការគ្រប់គ្រងផ្សេងពីគ្នាផងដែរ។ ដូចគ្នានេះដែរ ប្រជាពលរដ្ឋដែលចំណាកស្រុកដែលជាទូទៅជាអ្នកក្រីក្រនឹងបាត់បង់ឱកាសកាន់កាប់ដីរបស់ខ្លួន ដែលមានដោយស្របច្បាប់ ដោយសារមិនបានដឹងព័ត៌មានទាន់ពេលវេលា។
- យុទ្ធនាការចុះបញ្ជីដីលក្ខណៈជាប្រព័ន្ធដែលគ្របដំណ្តប់ទាំងដីរដ្ឋ ដីកាន់កាប់ឯកជន ហើយមានអ្នកពាក់ព័ន្ធច្រើន ជាពិសេសនៅតំបន់ជនជាតិដើមភាគតិច អាចនាំឱ្យមានការប្រទាញប្រទង់គ្នារវាងពលរដ្ឋដែលចង់បានដីឯកជន និងជនជាតិដើមភាគតិចដែលចង់បានដីកម្មសិទ្ធិសមូហភាព។ ទោះបីអ្នកពាក់ព័ន្ធទាំងមន្ត្រីរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលមើលឃើញឱកាសល្អពីយុទ្ធនាការបែប

នេះ សម្រាប់លើកកម្ពស់សិទ្ធិជនជាតិដើមភាគតិច និងការរក្សាអត្តសញ្ញាណវប្បធម៌ ប្រពៃណី ការឈានទៅរកការបែកបាក់សាមគ្គីផ្ទៃក្នុងនៅក្នុងសហគមន៍ អាចជាកត្តារារាំង ឬអូសបន្លាយការចុះបញ្ជីដីសមូហភាពបាន។ នេះអាចជាការប៉ះពាល់ដោយផ្ទាល់ទៅដល់គម្រោង LASED III ដែលមានសមាសភាគមួយក្នុងចំណោមសមាសភាគឯទៀតគឺ មានគោលបំណងចុះបញ្ជីដីសមូហភាពសម្រាប់សហគមន៍ទាំងឡាយណាដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត។

- សមសភាគមួយទៀតនៃ គម្រោង LASED III គឺការផ្តល់ដីសម្បទានសង្គមកិច្ចដល់ជនក្រីក្រ គ្មានដីដោយបែងចែកដីឯកជនរបស់រដ្ឋ។ យុទ្ធនាការនៃការបែងចែកដីដូចនៅខេត្តមណ្ឌលគិរីនេះ ត្រូវបានមើលឃើញថា មិនប៉ះពាល់ដល់ដីបម្រុងទុករបស់រដ្ឋ សម្រាប់គោលបំណងសម្បទានសង្គមកិច្ចលើកក្រោយនោះទេ។ អ្វីដែលសំខាន់នោះ សម្បទានដែលកំពុងតែមានស្រាប់នេះគិតចាប់តាំងពីចាប់ផ្តើមរហូតដល់ដំណាច់ឆ្នាំ ២០២១ ដែលជាការបញ្ចប់នៅគម្រោង LASED II នោះគឺអាចសម្បទានិកខ្លះរស់នៅលើដីដែលបានបែងចែកគ្រប់ ៥ឆ្នាំហើយ អាចត្រូវបានវាស់វែងប្រគល់ប័ណ្ណកម្មសិទ្ធិ រាល់ពេលដែលមានយុទ្ធការ ចូលមកដល់។ បញ្ហាស្ថិតនៅត្រង់ថា តើអ្នកដែលរស់នៅលើដីដែលបានបែងចែកមិនទាន់គ្រប់ ៥ឆ្នាំហើយ អាចនឹងត្រូវវាស់វែង ឬយ៉ាងណា ក្នុងខណៈពេលដែលយុទ្ធនាការចុះវាស់ដីទូទាំងខេត្តដូចករណីនៅមណ្ឌលគិរីស្រាប់?
- នៅក្នុងយុទ្ធនាការនៅខេត្តមណ្ឌលគិរីនេះ មិនដូចនៅក្នុងយុទ្ធនាការនៃបទបញ្ហា ០១ នោះទេ ។ នៅពេលនេះឱកាសមានការបើកចំហរយ៉ាងទូលំទូលាយក្នុងការរួមចំណែកផ្សព្វផ្សាយ ចូលរួមក្នុងដំណើរការវាស់វែង និងផ្តល់យោបល់អំពីជម្រើសល្អ និងបរិបទមូលដ្ឋាន ដើម្បីឱ្យមន្ត្រីវាស់វែងបានយល់ដឹង។ ក្នុងខណៈដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំក្រុមការងារចាត់ចែង និងចុះវាស់វែង ក្រសួងបរិស្ថានក៏មានរៀបចំក្រុមការងារសម្រាប់ត្រួតពិនិត្យ សិក្សា និងចងក្រងឯកសារទាក់ទងទៅនឹងប្រជាពលរដ្ឋដែលរស់នៅ និងអាស្រ័យផលនៅក្នុងដែនតំបន់ការពារធម្មជាតិ ។ ដូចគ្នានេះដែរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានបែងចែកជាក្រុមការងារចុះស្រាវជ្រាវ និងផ្ទៀងផ្ទាត់ទិន្នន័យដីព្រៃ ដែលប្រជាពលរដ្ឋកាន់កាប់អាស្រ័យផលជាក់ស្តែងដែរ។ ទាំងនេះ ជាយន្តការបញ្ចៀស ការវាស់វែងដីត្រួតស៊ីគ្នា ដោយមានការផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋដែលរស់នៅជាក់ស្តែង និងការធានាបាននូវការការពារធនធនធម្មជាតិដែលជាទីអាស្រ័យផល របស់ប្រជាពលរដ្ឋ។ លើសពីនេះទៀត រដ្ឋបាលស្រុកក៏មានការិយាល័យរង់ចាំទទួលរាល់ពាក្យបណ្តឹង ដើម្បីដោះស្រាយ មុនពេលធ្វើការវាស់វែង។

## អនុសាសន៍

យោងតាមបទពិសោធន៍កន្លងមក និងតាមការជជែកគ្នាក្នុងដំណើរការយុទ្ធនាការរយៈពេលជិតមួយសប្តាហ៍មកនេះ យើងសូមលើកជាអនុសាសន៍សម្រាប់ការរួមចំណែកធ្វើឱ្យមានប្រសិទ្ធភាពលើការងារវាស់វែងចុះបញ្ជី

ដីរដ្ឋ ចុះបញ្ជីដីប្រជាពលរដ្ឋ និង ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចសម្រាប់ដំណើការបច្ចុប្បន្ន ក៏ដូចជាអនាគត ដូចខាងក្រោមៈ

## ចំពោះរាជរដ្ឋាភិបាល និងថ្នាក់ក្រោមជាតិ

- គួរមានការពិភាក្សាអំពីដំណើរការនៃយុទ្ធនាការបែងចែកដីធ្លី ដោយមានការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល ដើម្បីឱ្យមានការជជែកអំពីផែនការលម្អិត និងកំណត់ពេលរៀបចំឱ្យបានគ្រប់គ្រាន់ល្អជាងយុទ្ធនាការនៅមណ្ឌលគិរី។
- គួរឆ្លុះបញ្ចាំងមេរៀនសំខាន់ៗនៃយុទ្ធនាការ ដោយសារមានសមាសភាព មន្ត្រីរដ្ឋាភិបាល តំណាងសហគមន៍ជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិល ដែលបានចូលរួមក្នុងដំណើរការ ដោយចងក្រងជាមេរៀនជាក់លាក់ មុននឹងឈានទៅការចុះបញ្ជីជាប្រព័ន្ធនៅតំបន់ ឬខេត្តដទៃទៀត។
- ក្រុមមន្ត្រីវាស់វែងតាមគោលដៅ គួរទទួលបាននូវវគ្គណែនាំតម្រង់ទិសអំពីបរិបទនៃសហគមន៍មូលដ្ឋាននិង ជនជាតិដើមភាគតិច និងបែបផែននៃការគ្រប់គ្រងដីធ្លីផ្សេងៗរួមមានៈ ការកំណត់បែងចែកតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ (តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព តំបន់សហគមន៍) ការចុះបញ្ជីដីសមូហភាពតាមអនុក្រឹត្យលេខ ៨៣ សហគមន៍តំបន់ការពារធម្មជាតិ ។ល។) មុនពេលចាប់ផ្តើមដំណើរការ។
- មេភូមិ មេឃុំ រួមជាមួយអ្នកពាក់ព័ន្ធ ជាពិសេសអង្គការសង្គមស៊ីវិលតាមគោលដៅ គួរផ្សព្វផ្សាយអំពីការត្រៀមចូលរួម និងការរៀបចំឯកសារថតចម្លងទុកជាមុនស្រាប់ បញ្ជីឈ្មោះអ្នកកាន់កាប់ដី ការបោះតម្រុយព្រំដីជាមុនដើម្បីងាយស្រួលក្រុមវាស់វែងដី ។ តាមពិត ដីកម្មសិទ្ធិសមូហភាពមានស្រាប់មិនចាំបាច់វាស់វែងទេ ប៉ុន្តែត្រូវធ្វើឯកសារវិនិច្ឆ័យបន្ថែមជាទម្រង់កម្មសិទ្ធិសមូហភាពសម្រាប់ដីបានចូលកាន់កាប់ថ្មីក្រៅដីសហគមន៍។ ដូច្នេះ គេចាំបាច់វាស់វែង និងរៀបចំឯកសារវិនិច្ឆ័យតែអ្នកទាំងឡាយណាដែលកាន់កាប់ក្រៅដីសហគមន៍ជនជាតិដើមភាគតិចប៉ុណ្ណោះជាពិសេសគឺសម្រាប់អ្នកមិនមែនជាសមាជិកសហគមន៍ ហើយការផ្តល់កម្មសិទ្ធិឯកជនគួរអនុវត្តតាមសារាចរលេខ០៦ របស់រាជរដ្ឋាភិបាល សរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩។
- អាជ្ញាធរមូលដ្ឋានគួរផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានពេលគ្រប់គ្រាន់សម្រាប់សហគមន៍ចូលរួម ជាពិសេសលើការយល់ដឹងអំពីយន្តការនៃការដាក់ពាក្យបណ្តឹង។ ជាក់ស្តែង ដីសហគមន៍ដែលចុះបញ្ជីជាសមូហភាពហើយ និងកំពុងចុះបញ្ជីត្រូវបានលក់ ចាត់ទុកជាករណីវិវាទដែលត្រូវដោះស្រាយតាមរយៈការដាក់ពាក្យបណ្តឹងទៅគណៈកម្មការដោះស្រាយវិវាទដីធ្លី ដោយមកដាក់នៅមន្ទីរ ឬកន្លែងប្រចាំការតាមស្រុក គេហៅថា ការិយាល័យនីតិកម្ម និងដោះស្រាយវិវាទនៃរដ្ឋបាលស្រុក។
- គួររៀបចំឱ្យមានសេចក្តីព្រាងលទ្ធផលនៃការវាស់វែងដីនឹងឆ្លុះបញ្ចាំងអំពីចំណាត់ថ្នាក់ដី (ដីសាធារណៈ និងដីឯកជនរបស់រដ្ឋ) និងផែនទីកំណត់បែងចែកតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិក្នុងខេត្តមណ្ឌលគិរីដោយថ្នាក់ដឹកនាំក្រសួងទាំងបួនផ្អែកលើលទ្ធផលសិក្សាស្រាវជ្រាវរបស់ក្រុមការងារ។

## ចំពោះសហគមន៍ ឬប្រជាពលរដ្ឋ

- សហគមន៍ជនជាតិដើមភាគតិចដែលមានប័ណ្ណកម្មសិទ្ធិត្រូវបង្ហាញចំនួនសមាជិកសហគមន៍ ក្បាលដី ទីតាំងដី ឬទីកន្លែងមានវិវាទដល់មន្ត្រីវាស់វែងដើម្បីដោះស្រាយវិវាទទាន់ពេល។ ការកាប់រានដីព្រៃថ្មីក្នុងអំឡុងពេលក្រោយការចុះបញ្ជីដី សហគមន៍គួរដាក់ពាក្យស្នើសុំជាកម្មសិទ្ធិសមូហភាពបន្ថែម (ជាប្រភេទដីបម្រុងទុកដូរវេណដំណាំ)។
- ថ្នាក់ដឹកនាំសហគមន៍ គួរជួយពន្យល់សមាជិកសហគមន៍ជនជាតិដើមភាគតិចអំពី សារៈសំខាន់ និងឱកាសដែលមាននៅពេលនេះ សម្រាប់ចុះបញ្ជីដីសមូហភាព ស្របតាមគោលនយោបាយ និងច្បាប់ជាធរមាន។ តែក្នុងករណីដែលសមាជិកសហគមន៍ជនជាតិដើមភាគតិចដែលចង់កម្មសិទ្ធិឯកជនត្រូវបំពេញសំណុំបែបបទចាកចេញស្របតាមលក្ខន្តិកៈសិន ទើបធ្វើការកាត់ចំណែកដែលត្រូវទទួលបានតាមនីតិវិធីពេលក្រោយស្របតាមអនុក្រឹត្យលេខ ៨៣ អនុក្រឹត្យលេខ១១៨ និងសារាចរលេខ០៦ របស់រាជរដ្ឋាភិបាល សរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩។
- សហគមន៍គួរតែមានការបង្ហាញអត្តសញ្ញាណ និងបោះតម្រុយព្រំឱ្យបានទុកជាមុន ព្រមទាំងប្រមូលឯកសារចាំបាច់ត្រៀមទុក (សហគមន៍ខ្លះខ្វះឯកសារ ឬមានឈ្មោះខុសគ្នា ធ្វើឱ្យមន្ត្រីមានការពិបាក ឬប្តីប្រពន្ធ ឬក៏អ្នកជាប់ព្រំមិននៅជុំគ្នា...) ។
- សហគមន៍ដែលមានលិខិតទទួលស្គាល់អត្តសញ្ញាណរួចហើយ ឬមិនទាន់មានឯកសារគ្រប់គ្រាន់ត្រូវរៀបចំដាក់ពាក្យទៅក្រុមការងារវាស់វែងដី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ។
- សហគមន៍ដែលមិនទាន់បានការកំណត់ស្វ័យអត្តសញ្ញាណពីក្រសួងអភិវឌ្ឍន៍ជនបទ គួររៀបចំប្រជុំពិភាក្សាដាច់ដោយឡែកអំពី ការឯកភាពជាតិពន្ធុសង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។ បន្ទាប់មក រកឱកាសជួបប្រជុំជាមួយមន្ត្រីវាស់វែង ដើម្បីបង្ហាញបំណងចង់បានកម្មសិទ្ធិរបស់ខ្លួន។

## ចំពោះអង្គការសង្គមស៊ីវិល

- នេះជាឱកាសល្អដែលអង្គការសង្គមស៊ីវិល ជាពិសេសអង្គការដែលធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច អាចជួយផ្តល់ព័ត៌មាន ឬយោបល់ដល់ក្រុមការងារវាស់វែង ព្រោះអង្គការមានការប្រាស័យទាក់ទងល្អជាមួយសហគមន៍ស្រាប់ និងអាចអញ្ជើញប្រជាពលរដ្ឋឱ្យមកចូលរួមបានច្រើន។
- កសាងបញ្ជីឈ្មោះអ្នកកាន់កាប់ដី ដោយមន្ត្រីអង្គការ ជាការប្រសើរ និងការបែងចែកក្រុមគ្រួសារស្របតាមចំនួនក្រុមការងារចុះវាស់ នៅតាមសហគមន៍នីមួយៗ។
- ពង្រឹងផ្សព្វផ្សាយ និងបន្តសិក្សាស្រាវជ្រាវអ្នកទិញលក់ដី នៅក្នុងតំបន់សហគមន៍តំបន់ការពារដែរ ក្នុងស្ថានភាពដែលធនធានប្រឈមការបាត់បង់។

- សម្របសម្រួលជាមួយប្រធានសហគមន៍ និងមេភូមិដើម្បីកសាងតារាងអត្តសញ្ញាណអ្នកកាន់កាប់ដី (បញ្ជីឈ្មោះ ទំហំដី ពេលវេលាកាន់កាប់ ប្រភេទដំណាំអាស្រ័យផល) នៅក្រៅដីសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជី ឬកំពុងដំណើរការ និងសហគមន៍តំបន់ការពារធម្មជាតិ។
- សិក្សាប្រមូលព័ត៌មានជាមួយមេភូមិ ប្រធានសហគមន៍ ឬអ្នកពាក់ព័ន្ធផ្សេងទៀតអំពីអ្នកខាងក្រៅដែលបានទិញដូរដីកម្មសិទ្ធិសមូហភាពសហគមន៍ ឬដីសហគមន៍តំបន់ការពារធម្មជាតិ។
- សម្របសម្រួលជាមួយអ្នកកាន់កាប់ដីក្បែរខាងឱ្យបោះតម្រុយព្រំ (បាញ់ថ្នាំសម្គាល់ព្រំ) ជាមុន និងរង់ចាំ ឬជូនបង្ហាញផ្លូវក្រុមការងារវាស់វែងដី។
- ជួយរំលឹកមន្ត្រីតំបន់ការពារធម្មជាតិ និងមន្ត្រីពាក់ព័ន្ធ ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ កត់ត្រាស្រង់ទិន្នន័យឆ្នាំកាន់កាប់ និងគម្របព្រៃតាមឆ្នាំនៅទីវាលជាក់ស្តែង។

## យោបល់រួម

យុទ្ធនាការសម្រាប់វាស់វែងដីធ្លីនៅខេត្តមណ្ឌលគិរីជាលក្ខណៈប្រព័ន្ធ បានធ្វើឱ្យមានការចាប់អារម្មណ៍ ពីសំណាក់ភ្នាក់ងារអភិវឌ្ឍន៍ ជាពិសេសអង្គការសង្គមស៊ីវិល។ វាជាដំណើរការដ៏សំខាន់ សម្រាប់ដោះស្រាយបញ្ហារំលោភយកដីធ្លីរដ្ឋ និងដីឯកជន ព្រមទាំងវិវាទទាក់ទងដីធ្លីផ្សេងៗទៀតដែលបានអូសបន្លាយមកជាច្រើនឆ្នាំ។ ទោះបីមានការសាទរចំពោះដំណើរការនេះ អង្គការសង្គមស៊ីវិល មានក្តីព្រួយបារម្ភសម្រាប់ដំណើរការនៅក្នុងខេត្តមណ្ឌលគិរីនេះ ក៏ដូចជាការយុទ្ធនាការស្រដៀងគ្នានេះ នៅលើកក្រោយៗទៀតដែរ។ ពិតណាស់ យុទ្ធនាការនេះ មិនដូចបទបញ្ជា ០១នោះទេ ព្រោះមិនមានការរារាំងមិនឱ្យចូលរួមពីសំណាក់អ្នកពាក់ព័ន្ធនោះទេ តែការរៀបចំសម្រាប់អនុវត្តន៍ហាក់ដូវជាមានលក្ខណៈបន្ទាន់ ដូចបានឃើញលិខិតបទដ្ឋានដែលចេញជាហូរហែដោយក្រសួងពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិ ដែលសុទ្ធតែធ្វើឡើងក្នុងខែកក្កដា ឆ្នាំ ២០២០ ទាំងអស់ ដែលជាហេតុធ្វើឱ្យអង្គការសង្គមស៊ីវិល រៀបចំត្រៀមខ្លួន និងធនធាន សម្រាប់ចូលរួមមិនបានពេញលេញ ហើយសហគមន៍ ព្រមទាំង អាជ្ញាធរភូមិឃុំ ហាក់ដូចជាមានពេលសម្រាប់ផ្សព្វផ្សាយ រីឯមន្ត្រីវាស់វែងក៏មិនមានឱកាសឈ្វេងយល់អំពីបរិបទមូលដ្ឋានជាមុនឱ្យបានស៊ីជម្រៅ។ មិនត្រឹមតែប៉ុណ្ណោះ អ្នកគ្រប់គ្រងអ្នកអនុវត្ត និងអ្នកពាក់ព័ន្ធក្នុងយុទ្ធនាការនេះ គួរតែមានការយល់ស្របគ្នាថា ការធ្វើឱ្យមានសុខដុមនីយកម្មនៃអនុក្រឹត្យទាំងបី ពោលគឺមិនគួរយកតែអនុក្រឹត្យលេខ ៤៦ (ការចុះបញ្ជីដីជាប្រព័ន្ធ) ទើបការអនុវត្តប្រកបដោយប្រសិទ្ធភាពទៅបាន។ ក្នុងដំណាក់កាលនៃការប្រកាសផ្អាកបណ្តោះអាសន្ននេះ វាជាឱកាសសម្រាប់អ្នកពាក់ព័ន្ធ ជាពិសេស អង្គការសង្គមស៊ីវិល ធ្វើការជួបជុំ ឆ្លុះបញ្ចាំងនូវការអនុវត្ត ថ្មីៗនេះ ហើយយើងនៅតែបន្តប្តេជ្ញាចិត្តចូលរួមក្នុងដំណើរការនេះ និងលើកក្រោយទៀតជាមួយរាជរដ្ឋាភិបាល រួមជាមួយអនុសាសន៍ខ្លះៗ ដូចបានលើកឡើងខាងលើ សម្រាប់ដាក់ជូនរាជរដ្ឋាភិបាល និងមន្ត្រីគ្រប់លំដាប់ថ្នាក់យកមកពិចារណា។

**បញ្ជីឈ្មោះស្ថាប័នដែលបានចូលរួម**

១. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា NGO Forum
២. អង្គការសមាគមខ្មែរលើរតនគិរី Highlander Association
៣. សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា CIYA
៤. បណ្តាញសមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិច IRAM
៥. អង្គការពន្លកខ្មែរ PKH
៦. អង្គការអនុផលព្រៃឈើ NTFP
៧. អង្គការកម្មវិធីផ្លាស់ប្តូរបទពិសោធន៍អនុផលព្រៃឈើ NTFP-EP
៨.អង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ CLEC
៩. អង្គការអប់រំបរិស្ថាន និងសុខភាព EHE
១០. អង្គការភូមិខ្ញុំ MVi
១១. អង្គការជនជាតិដើមភាគតិចកម្ពុជា ICSO
១២. ក្រុមការងារពង្រឹង និងអភិវឌ្ឍសហគមន៍ CEDT
១៣. អង្គការជំនួយប្រជាពលរដ្ឋណ័រវេ NPA
១៤. អង្គការ HEKS
១៥. អង្គការ Oxfam
១៦. ការិយាល័យឧត្តមស្នងការសេហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា OHCHR
១៧. អង្គការ ADIC ( សម្របសម្រួល និងធ្វើរបាយការណ៍ )